# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៣០...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ហ្គោលហ្វេមផាកស៊ីន

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលមាត្រា១ នៃអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច៤.១

នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

- យោងតាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**សម្រេច**

**មាត្រា១.-**

បង្កើត **តំបន់សេដ្ឋកិច្ចពិសេស ហ្គោលហ្វេមផាកស៊ុន** (GOLDFAME PAK SHUN SEZ) ដែលមានទីតាំងស្ថិតនៅឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល ។

**មាត្រា២.-**

**តំបន់សេដ្ឋកិច្ចពិសេស ហ្គោលហ្វេមផាកស៊ុន** មានទំហំ ប្រាំពីររយហាសិបពាន់ ប្រាំពីររយប៉ែតសិបប្រាំបីម៉ែត្រក្រឡា ដូចមានប្លង់ទីតាំងព្រំប្រទល់ភូមិសាស្ត្រក្នុងឧបសម្ព័ន្ធ ដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ច ជាចំណែកភ្ជាប់អនុក្រឹត្យនេះ ។

**មាត្រា៣.-**

ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេស ហ្គោលហ្វេមផាកស៊ុន** ដូចមានកំណត់ក្នុងមាត្រា ២ ជាកម្មសិទ្ធិឯកជនស្របច្បាប់របស់ក្រុមហ៊ុន ។

**មាត្រា៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃតំបន់សេដ្ឋកិច្ចពិសេសនេះ នឹងស្ថិតក្រោមវិសាលភាពនៃច្បាប់ និងបទប្បញ្ញត្តិនានានៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ

និងថាមពល រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តកណ្តាល និងក្រុមហ៊ុន ហ្គោលហ្វេមផាកស៊ុន អេសអ៊ីហ្សិត ខូអិលធីឌី ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន
សម្តេចនាយករដ្ឋមន្ត្រីដើម្បីសូមចុះហត្ថលេខា
អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
អគ្គលេខាធិការ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

សុខ ចិន្តា

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- ឯកសារ-កាលប្បវត្តិ